ច្បាប់ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ នៅរដ្ឋម៉ាសាឈូសេត

ការិយាល័យអគ្គរដ្ឋអាជ្ញាប្រចាំរដ្ឋម៉ាសាឈូសេត
អ្នកស្រី **ម៉ូរ៉ា ហ៊ីលី**

លេខទូរស័ព្ទ Hotline សម្រាប់បញ្ហាយុត្តិធម៌ការងារ
(617) 727-3465
TTY (617) 727-4765

www.mass.gov/ago/fairlabor

ច្បាប់រដ្ឋ តម្រូវឲ្យនិយោជកទាំងអស់បិទជំនាងនេះ នៅកន្លែងធ្វើការត្រង់កន្លែងដែលងាយមើលឃើញ។
M.G.L Chapter 151, Section 16;
454 C.M.R 27.07(1)

ប្រាក់ឈ្នួលអប្បបរមា
M.G.L. Chapter 151, Sections 1, 2, 2A, and 7

នៅរដ្ឋម៉ាសាឈូសេត កម្មករទាំងអស់ ត្រូវសន្មត ថាជានិយោជិត។ ប្រាក់ឈ្នួលអប្បបរមា ត្រូវអនុវត្តចំពោះនិយោជិត**ទាំងអស់** លើកលែងតែ៖

- កម្មករវិស័យកសិកម្ម (៨ ដុល្លារក្នុងមួយម៉ោង ជាប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករផ្នែកកសិកម្មស្ទើរតែទាំងអស់)
- សមាជិកនៃក្រុមសាសនាជាក់លាក់ណាមួយ
- កម្មករកំពុងស្ថិតក្នុងដំណាក់កាលបណ្តុះបណ្តាលអង្គការអប្បី បុអង្គការមិនរកប្រាក់កម្រៃ ឬអង្គការសិស្សនា និង
- បុគ្គលិកផ្នែកទីផ្សារ ដែលត្រូវធ្វើការនៅខាងក្រៅ

កាលបរិច្ឆេទចាប់អនុវត្ត	ប្រាក់ឈ្នួលអប្បបរមា	អត្រាកម្រៃសៅ
១ មករា ២០១៧	១១ ដុល្លារ	៣,៧៥ ដុល្លារ
១ មករា ២០១៩	១២ ដុល្លារ	៤,៣៥ ដុល្លារ
១ មករា ២០២០	១២,៧៥ ដុល្លារ	៤,៩៥ ដុល្លារ
១ មករា ២០២១	១៣,៥០ ដុល្លារ	៥,៥៥ ដុល្លារ
១ មករា ២០២២	១៤,២៥ ដុល្លារ	៦,១៥ ដុល្លារ
១ មករា ២០២៣	១៥ ដុល្លារ	៦,៧៥ ដុល្លារ

លុយធីប
M.G.L. Chapter 149, Section 152A; M.G.L. Chapter 151, Section 7

"អត្រាសៅ"តាមម៉ោង អនុវត្តចំពោះកម្មករ ដែលផ្តល់សេវាជូនអតិថិជន និង រកប្រាក់ធីបបានលើសពី ២០ ដុល្លារក្នុងមួយខែ។ លុយធីបតាមម៉ោងគិតមធ្យម បុកនឹងអត្រាសេវាតាមម៉ោង ត្រូវបើកឲ្យកម្មករ គឺត្រូវស្មើនឹងប្រាក់ឈ្នួលអប្បបរមា (ឬច្រើនជាងនេះ)។ អ្នកគ្រប់គ្រង មេការ និង ម្ចាស់ មិនត្រូវយកចំណែកលុយធីបរបស់និយោជិតខ្លួន ជាដាច់ខាត។
លុយធីប និង ថ្លៃសេវាបន្ថែម ដែលមានក្នុងវិក្កយបត្រ ត្រូវប្រគល់ជូនបុគ្គលិកតែគ្រុ អ្នកលើកស្រា ឬ និយោជិតផ្នែកបម្រើសេវាដទៃទៀត។ លុយធីបមួ គឺសម្រាប់តែបុគ្គលិកកត់តុ អ្នកលើកស្រា និង និយោជិតផ្នែកបម្រើសេវាដទៃទៀតប៉ុណ្ណោះ។

ប្រាក់បន្ថែមម៉ោង
M.G.L. Chapter 151, Sections 1A and 1B

ជាទូទៅ និយោជិត ធ្វើការលើសពី ៤០ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវតែទូទាត់បានប្រាក់បន្ថែមម៉ោង។ ប្រាក់បន្ថែមម៉ោងនេះ គឺយ៉ាងតិចត្រូវស្មើនឹង ១,៥ ដែ្លនៃប្រាក់ម៉ោងធម្មតា ដែលធ្វើលើសពី ៤០ ម៉ោងក្នុងមួយសប្តាហ៍នោះ។
ចំពោះនិយោជិតខ្លះ ដែលទទួលប្រាក់តាម "អត្រានៃសេវា" ប្រាក់បន្ថែមម៉ោងនេះ គឺស្មើនឹងប្រាក់ឈ្នួលអប្បបរមា គុណនឹង ១,៥ មិនមែនគុណនឹងអត្រានៃសេវានោះទេ។ ឧទាហរណ៍ តាមច្បាប់រដ្ឋ ក្យាងរ ឬ កន្ត្រៃខ្លះ គេលើកលែងប្រាក់ម៉ោងបន្ថែមនេះ។ ព័ត៌មានអំពីការលើកលែងនេះ សូមមើលនៅ *www.mass.gov/ago/fairlabor* ឬទូរស័ព្ទទៅផ្នែកយុត្តិធម៌ការងារ នៃការិយាល័យអគ្គរដ្ឋអាជ្ញាលេខ (៦១៧)៧២៧-៣៨៦៥។

ការបើកប្រាក់ឈ្នួល
M.G.L. Chapter 149, Section 148; 454 C.M.R. 27.02

ច្បាប់មានចែង អំពីថាតើនិយោជិតត្រូវបើកប្រាក់ពេលណា បើកតាមមធ្យោបាយណា និង បើកប្រាក់អ្វី។ ប្រាក់ខែ (ឬប្រាក់ឈ្នួល)របស់និយោជិត បុក្រុមទាំងម៉ោងបានធ្វើការទាំងអស់ រួមទាំងប្រាក់ធីប ប្រាក់ពេលសម្រាលម្តែ ប្រាក់ថ្ងៃឈប់សម្រាកបុណ្យ និង ប្រាក់កម្រៃជើងសារដែលបានកំណត់ច្បាស់លាស់រួច ត្រូវតែបើកឲ្យនិយោជិត។
និយោជិតធ្វើការគិតម៉ោង ត្រូវបើកប្រាក់ឈ្នួលរាល់សប្តាហ៍ ឬពីរសប្តាហ៍ម្តង។ ថ្ងៃបើកលុយ គឺ ៦ ឬ ៧ ថ្ងៃក្រោយបំពេញការងារួច អាស្រ័យលើចំនួនថ្ងៃ ដែលនិយោជិត បានធ្វើការក្នុងមួយសប្តាហ៍ តាមប្រតិទិន។
និយោជិត ដែល*ឈប់ពីការងារ* ត្រូវបើកលុយពេញ នៅថ្ងៃបើកលុយបន្ទាប់តាមធម្មតា ឬបើកនៅថ្ងៃស្អែកដែរបុង ក្រោយឈប់ពីការងារ (ប្រសិនបើគ្មានថ្ងៃបើកលុយទៀងទាត់)។ និយោជិត*ដែលបញ្ឈប់ឬ រំសាយ*ត្រូវបើកលុយពេញ នៅថ្ងៃធ្វើការចុងក្រោយ។

ព័ត៌មានអំពីបង្កាន់ដៃបើកលុយ
M.G.L. Chapter 149, Section 148

និយោជិតទាំងអស់ ត្រូវទទួលបានបង្កាន់ដៃ អំពីការបើកប្រាក់ឈ្នួល ដោយមានឈ្មោះកន្លែងធ្វើការ និង និយោជិត កាលបរិច្ឆេទបើកលុយ (ខែ, ថ្ងៃ និង ឆ្នាំ) ចំនួនម៉ោងដែលបានធ្វើការ ថ្លៃឈ្នួលក្នុងមួយម៉ោង ថ្លៃកាត់ប្រាក់ខែ ឬ ឡើងប្រាក់ខែ ក្នុងអំឡុងពេលបើកលុយនោះ។

ការកាត់ប្រាក់ខែ
M.G.L. Chapter 149, Section 148; 454 C.M.R. 27.05

និយោជិតមិនអាចកាត់ប្រាក់ខែពីនិយោជិតណាម្នាក់បានឡើយ លើកលែងតែច្បាប់អនុញ្ញាត (ដូចជាការកាត់ពន្ធរដ្ឋ និង ពន្ធថ្នាក់ជាតិ) ឬ និយោជិត សុំឲ្យកាត់ប្រាក់ខែគាត់ទុក (ដើម្បីដាក់ក្នុងគណនីសន្សំជាដើម)។
និយោជក មិនអាចយកប្រាក់ខែនិយោជិត ដើម្បីចេញថ្លៃចំណាយលើមុខជំនួញប្រចាំថ្ងៃរបស់ខ្លួនបាននោះឡើយ (ឧទាហរណ៍ គ្រឿងផ្គត់ផ្គង់សម្ភារៈ ឬ ឧបករណ៍ផ្សេង។ ដែលចាំបាច់សម្រាប់ការងាររបស់និយោជិត)។ និយោជក ដែលតម្រូវឲ្យនិយោជិតទិញ ឬ ជួលឯកសណ្ឋាន ត្រូវតែទូទាត់សងប្រាក់នោះវិញ ទៅដល់និយោជិត។
ច្បាប់តំណាងចែងកម្រិតចំនួនប្រាក់ និង វិធីដែលនិយោជក អាចកាត់ប្រាក់ខែនិយោជិត សម្រាប់ថ្លៃស្នាក់នៅ និង អាហារដែលនិយោជកផ្តល់ឲ្យ។

ម៉ោងដែលបានធ្វើការ
454 C.M.R. 27.02

ម៉ោងដែលបានធ្វើការ ឬ "ម៉ោងធ្វើការ" គឺគិតម៉ោងទាំងអស់ ដែលនិយោជិតត្រូវបំពេញការងារ នៅទីតាំងរបស់និយោជក ឬទីតាំងផ្សេង និង ការងារនៅមុន និង ក្រោយវេនធ្វើការ ដើម្បីបង្ក្រប់កិច្ចការ។

ម៉ោងសម្រាកស្រស់ស្រូបអាហារ
M.G.L. Chapter 149, Sections 100 and 101

និយោជិតភាគច្រើន ដែលធ្វើការលើសពី ៦ម៉ោង ត្រូវមានពេលសម្រាក ៣០នាទី ដើម្បីស្រស់ស្រូបអាហារ។ ក្នុងម៉ោងសម្រាកហូបបាយនេះ និយោជិតត្រូវមានសេរីភាពផុតពីការងារ និង មានសិទ្ធិចេញក្រៅកន្លែងធ្វើការបាន។ ប្រសិនបើនិយោជកស្នើឲ្យនិយោជិតធ្វើការ ឬ មានវត្តមាននៅកន្លែងធ្វើការក្នុងម៉ោងសម្រាកបាយនោះ ហើយនិយោជិតយល់ព្រម និយោជិតត្រូវតែទូទាត់ប្រាក់ម៉ោងនៅពេលបាយនោះ។

កំណត់ហេតុប្រាក់ខែ
M.G.L. Chapter 151, Section 15

កំណត់ហេតុប្រាក់ខែ ត្រូវមានឈ្មោះនិយោជិត អាសយដ្ឋាន តួនាទី ចំនួនប្រាក់ឈ្នួលដែលត្រូវបើក និង ម៉ោងដែលបានធ្វើការ (ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍)។ និយោជក ត្រូវរក្សាកំណត់ហេតុប្រាក់ខែ សម្រាប់រយៈពេល ៣ ឆ្នាំ។ និយោជិត មានសិទ្ធិមើលកំណត់ហេតុប្រាក់ខែរបស់ខ្លួន ទៅតាមពេលវេលា និង ទីកន្លែងសមស្រប។

ឈប់សម្រាកពេលឈឺ
M.G.L. Chapter 149, Section 148C

និយោជិតស្ទើរតែទាំងអស់ មានសិទ្ធិទទួលបានការឈប់សម្រាកពេលឈឺមួយម៉ោង រាល់ការបំពេញការងារបាន ៣០ ម៉ោង ហើយពួកគាត់អាចទទួលបានម៉ោងសម្រាកពេលឈឺនេះ ហួសដល់ ៤០ម៉ោងក្នុងមួយឆ្នាំ។ និយោជិតចាប់ផ្តើមសន្សំម៉ោងសម្រាកពេលឈឺ តាំងពីថ្ងៃធ្វើការដំបូង។ និយោជិតត្រូវតែទទួលបានម៉ោងសម្រាកពេលឈឺនេះ៖ ចាប់ពីចុងធ្វើការបាន ៩០ថ្ងៃ។
និយោជិត ដែលត្រូវទទួលបានម៉ោងសម្រាកឈឺពេលនេះ៖ អាចប្រើម៉ោងនេះបាន ដើម្បីគេច បុ កូន ប្រពន្ធ/ប្តី ឪពុក/ម្តាយ ឬ ឪពុក/ម្តាយក្មេក ឈឺ ឬស ឬ មានណាតជុំវិញខ្លួន។ ពួកគេក៏អាចប្រើម៉ោងសម្រាកពេលឈឺនេះ សម្រាប់ខ្លួនឯង ឬ កូន ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ។
និយោជិតត្រូវតែជូនដំណឹងនិយោជក មុននឹងប្រើម៉ោងសម្រាកពេលឈឺនេះ លើកលែងតែករណីបន្ទាន់។
និយោជិតដែលខកការងារបើថ្ងៃជាប់ៗគ្នា ត្រូវតែបង្ហាញសំបុត្រពេទ្យ ទៅឲ្យនិយោជក។

ការសម្រាកពេលឈឺ មានប្រាក់ខែ
និយោជិតមានបុគ្គលិក១១នាក់ ឬ ច្រើនជាងនេះ: *ត្រូវតែ*ផ្តល់ការម៉ោងសម្រាកពេលឈឺដោយមានប្រាក់ខែ។ និយោជិតដែលមានបុគ្គលិកក្រោម ១១នាក់ ត្រូវផ្តល់ម៉ោងសម្រាកពេលឈឺនេះ ប៉ុន្តែមិនចាំបាច់ផ្តល់ប្រាក់ខែ។

និយោជកមិនត្រូវរើសអើង
M.G.L. Chapter 149, Section 105A; M.G.L. Chapter 151B, Section 4

និយោជក មិនត្រូវផ្តល់ប្រាក់ឈ្នួលខ្ទង់និយោជិតតិចជាងគ្នា ចំពោះអ្នកមានភេទ សម្រាប់ការងារដូច ឬ ប្រហាក់ប្រហែលគ្នា។
និយោជកមិនត្រូវរើសអើង លើការជ្រើសបុគ្គលិក ផ្តល់ប្រាក់ឈ្នួល ឬ ផ្តិលប្រាក់ឯកន្លែងផ្សេងៗ ឬ លក្ខខណ្ឌការងារផ្សេងពីនេះ ដោយផ្អែកលើ៖

- ពូជសាសន៍ ឬ ពណ៌សម្បុរ
- សាសនា ដើមកំណើតជាតិសាសន៍ ឬ ពូជពង្ស
- ភេទ (រួមទាំងការមានផ្ទៃពោះ)
- សៅយ៉ោធា
- និន្នាការផ្លូវភេទ ឬ អត្តសញ្ញាណយេនឌ័រ ឬ រូបរាង
- ពិតមានអំពីតំណពូជ ឬ ពិការភាព
- អាយុ

ឈប់សម្រាកដែលចាំបាច់
M.G.L. Chapter 149, Section 52D

មានករណីខ្លះ និយោជិតមានសិទ្ធិឈប់សម្រាកមិនយកប្រាក់ខែ ហូតដល់ ២៤ម៉ោង រាល់ ១២ខែ សម្រាប់៖

- សកម្មភាពនៅសាលារបស់កូន
- ការណាត់ជួបពេទ្យទូទៅ ឬ ពេទ្យផ្នែកជួបរបស់កូន ឬ
- ការណាត់ជួបពេទ្យទូទៅ ឬ ពេទ្យផ្នែកជួបរបស់សាច់ញាតិជាមនុស្សចាស់ ឬ ការណាត់ជួបផ្សេងទៀត។

ឱ្យនិយោជិតមានសិទ្ធិឈប់សម្រាក ប៉ុន្តែមិនយកប្រាក់ខែ ឬ ប្រាក់ឈ្នួលក្នុងអំឡុងពេលនេះ ដែលមានរយៈពេលដល់ ២៤ម៉ោង ក្នុងរយៈពេល ១២ខែ ដែលនិយោជិតធ្វើការ។ ច្បាប់នេះមិនអនុញ្ញាតឲ្យនិយោជិតមានអត្ថប្រយោជន៍បន្ថែមទេ ដូចជាការឈប់សម្រាកដោយមានប្រាក់ខែ ឬ ការឈប់សម្រាកដោយមានប្រាក់ឈ្នួលជាដើម។

ប្រាក់ឈ្នួលការងារបន្ទាន់
454 C.M.R. 27.04(1)

និយោជិតស្ទើរតែទាំងអស់ ត្រូវទទួលបានប្រាក់ឈ្នួល ៣ម៉ោង ដែលមិនតិចជាងប្រាក់ឈ្នួលអប្បបរមា បើនិយោជិតនោះ ត្រូវនិយោជកឲ្យធ្វើការបន្ទាន់ ៣ម៉ោង ឬច្រើនម៉ោង និង បានទៅធ្វើការបន្ទាន់នោះតាមពេល បើទោះបីជាការងារនោះ ចប់មុនម៉ោងដែលកំណត់ក្តី។

សិទ្ធិកម្មករបណ្តោះអាសន្ន
M.G.L. Chapter 149, Section 159C

ដើម្បីជ្រាបព័ត៌មានអំពីកម្មករបណ្តោះអាសន្ន និង និយោជិត ដែលជួលតាមភ្នាក់ងារសេវាបុគ្គលិក សូមទូរស័ព្ទ៖ 617-626-6970 ឬបើករមើលគេហទំព័រ *www.mass.gov/dols.*

សិទ្ធិកម្មការតាមផ្ទះ
M.G.L. Chapter 149, Section 190

ដើម្បីជ្រាបព័ត៌មានអំពីសិទ្ធិកម្មករ ដែលធ្វើការតាមផ្ទះ៖ បោសជូត មើលក្មេង ដាំស្ល ចាត់ចែងផ្ទះ៖ មើលមនុស្សចាស់ ឬសេវាស្រដៀងនេះ សូមបើកមើលគេហទំព័រ *www.mass.gov/ago/DW.*

កម្មករមុខងារសាធារណៈនិង កម្មករសំណង់សាធារណៈ
M.G.L. Chapter 149, Section 26-27H

កម្មករដែលធ្វើការក្នុងគម្រោងសាងសង់សាធារណៈ និង សាធារណៈការដ្ឋាក់លាក់ដទៃទៀត ត្រូវតែទទួលបានប្រាក់ឈ្នួលអប្បបរមា ដែលកំណត់ដោយនាយកដ្ឋានបទដ្ឋានការងារ ផ្អែកលើប្រភេទការងារ ដែលធ្វើ។

ឈប់សម្រាកដោយសារអំពើហិង្សាក្នុងគ្រួសារ
M.G.L. Chapter 149, Section 52E

និយោជិតដែលជាជនរងគ្រោះ ឬ សមាជិកគ្រួសារគាត់ជាជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ ការបំពាន់ការផ្លូវភេទ ឬ ចាប់ជំរិត មានសិទ្ធិឈប់សម្រាក ១៥ថ្ងៃ ដើម្បីកែទម្រាចាំបាច់ ដូចជាថៃទាំសុខភាព ពីគ្រោះយោបល់ និង សុវាជនរងគ្រោះ ជំរុមកស្ថិតិភាព ការមើលថែកូនរបស់ខ្លួន និង ជិនួយផ្នែកច្បាប់ ដីកាការពារ និង ទៅតុលាការ។ ការសម្រាករនេះ អាចមានប្រាក់ខែ ឬ គ្មាន អាស្រ័យលើគោលការណ៍របស់និយោជក។ ច្បាប់នេះអនុវត្តសម្រាប់និយោជក ដែលមាននិយោជិត ៥០នាក់ ឬ លើសនេះ។

និយោជិតមានសិទ្ធិប្តឹង
M.G.L. Chapter 149, Section 150; M.G.L. Chapter 151, Sections 1B and 20

និយោជិតមានសិទ្ធិប្តឹងនិយោជកបរបស់ខ្លួន ដែលបំពានច្បាប់ ស្តីពីប្រាក់ឈ្នួល និង ម៉ោងធ្វើការ។
និយោជិតអាចប្តឹងជាលក្ខណៈបុគ្គល ឬ ពួកគាត់អាចប្តឹងនិយោជកបរបស់ខ្លួន ជាក្រុមបើពួកគាត់មានបណ្តឹងដូចគ្នា។ និយោជិតដែលឈ្នះក្តី និងទទួលបានប្រាក់ ដែលមិនទាន់បានបើក ថ្លៃខូតខាតសងជាប់ ថ្លៃជួលមែជាវិ និង ថ្លៃតុលាការ។
សំខាន់! និយោជិតអាចដាក់បណ្តឹងបាន ទៅតាមវេលាកំណត់តឹងរឹងមួយ។ ស្វើគ្រប់ករណី ពេលវេលាកំណត់ គឺ ៣ឆ្នាំក្រោយមានករណីបំពាន។

និយោជកមិនត្រូវសងសឹក
M.G.L. Chapter 149, Section 148A; M.G.L. Chapter 151, Section 19

ជាការខុសច្បាប់ បើនិយោជកដាក់ទណ្ឌកម្ម ឬរើសអើងនិយោជិត ដែលដាក់ពាក្យប្តឹង ឬ ព្យាយាមអនុវត្តសិទ្ធិ ដែលមានពន្យល់ក្នុងនេះ។
ច្បាប់ដែលពន្យល់ក្នុងនេះ ត្រូវអនុវត្តចំពោះគ្រប់កម្មករ មិនថាស្ថានភាពអ្នន្តោប្រវែស្ន័យាងណាទេ។ រួមទាំងកម្មករដែលគ្មានក្រដាសស្នាម។ បើនិយោជកការណ៍ ឬ តួអ្នកមានការណ៍ទៅតាជ្ញាធរអនុវត្តប្រវែន ដោយសារនិយោជិតប្តឹងអំពីការរំលោភសិទ្ធិ និយោជកនោះអាចត្រូវផ្តន្ទាទោស និង/ឬ អាចរងពិន័យផ្នែកវិជ្ជបញ្ជាវណ្ណី។

និយោជិតអាយុក្រោម ១៨ ឆ្នាំ--ពលកម្មកុមារ
M.G.L. Chapter 149, Sections 56-105

និយោជកទាំងអស់ នៅរដ្ឋម៉ាសាឈូសេត ត្រូវអនុវត្តតាមច្បាប់រដ្ឋ និង ច្បាប់ជាតិ សម្រាប់និយោជិតដែលអាយុក្រោម ១៨ឆ្នាំ (អនីតិជន)។ ច្បាប់ទាំងអស់នេះ ចែងអំពី *ពេលណា ទីណា* និង *រយៈពេលយូរប៉ុនណា* ដែលអនីតិជនអាចធ្វើការ។ ច្បាប់នេះក៏ចែងអំពីការងារ អនីតិជនមិនត្រូវធ្វើ។ **រាល់ការងារ សុទ្ធតែតម្រូវឲ្យមានលិខិតអនុញ្ញាតការងារ។ កម្មកររអាយុក្រោម ១៨ឆ្នាំ ស្នើតែទាំងអស់ ត្រូវមានលិខិតអនុញ្ញាតការងារ។ និយោជកត្រូវរក្សាទុកលិខិតអនុញ្ញាតការងារ របស់កម្មករ នៅក្នុងសំណុំឯកសារកន្លែងការងារ។ នីតិជនត្រូវបាក់ពាក្យសុំលិខិតអនុញ្ញាតការងារ ពីនាយកសាលារបស់គាត់។ សូមស្វែងយល់ព័ត៌មានបន្ថែម អំពីលិខិតអនុញ្ញាតការងារនេះ សូមទាក់ទងនាយកដ្ឋានការងារ និង បទដ្ឋាន តាមរយៈលេខទូរស័ព្ទ និង គេហទំព័រ៖** (617) 626-6975, or *www.mass.dols.gov.*

ការងារគ្រោះថ្នាក់ និង ការងារដែលអនីតិជន មិនត្រូវធ្វើ

អាយុ	មិនត្រូវធ្វើ	
16 & 17	• បើកយានយន្តស្ទើរគ្រប់ប្រភេទ ឬ ឡានលើកទំនិញ។ • ការងារកន្លែងដែលតម្រូវឲ្យនិយោជិតកាន់ ឬ ប្រើប្រាស់អាវុធ។ • ប្រើប្រាស់ ជូតសម្អាត ឬ ជួសជុលម៉ាស៊ីនដើរដោយថាមពល។	• ចាត់ចែង បម្រើ ឬ លោតគ្រឿងស្រវឹង។ • ធ្វើការនៅទីខ្ពស់ពីដី ៣០ ហ្វីត ឬ ខ្ពស់ជាងនេះ។
14 & 15	• ចម្អិនអាហារ (លើកលែងលើចង្ក្រានអាំងសាច់ ប្រើអគ្គសនី ឬ ហ្គាសដែលមានអណ្តាតភ្លើងមិនក្រៅ) ប្រើបង្ក្រានបំពង ឬ ឆ្នាំងដុតមាន់ ឬអាំងសាច់ ឬ ចង្ក្រានសម្ភាដើរដោយអគ្គីសនី។ • ប្រើប្រាស់ ជូតសម្អាត ឬ ជួសជុលម៉ាស៊ីនហាន់សាច់ ម៉ាស៊ីនកិនម៉ាស៊ីនកាត់ ម៉ាស៊ីនក្រឡុក កាំបិត ម៉ាស៊ីនលាយ។	• ការងារកន្លែងទូរគ្លាសេ ឬ កន្លែងក្លាសេសាច់ • រាល់ការងារដុតនំ • ការងារក្នុង ឬ ក្បែរពោងចេក ការដ្ឋានសំណង់ កន្លែងមេកានិច យានដ្ឋាន ផ្លូវក្រោមដី ឬ កន្លែងគ្រោះថ្នាក់ដទៃទៀត។
ក្រោម 14	• អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអនុញ្ញាត ឲ្យធ្វើការងារគ្រប់មុខ នៅរដ្ឋម៉ាសាឈូសេត ទោះក្នុងករណីណាក៏ដោយ។	

ម៉ោង និង កាលវិភាគ ដែលត្រូវហាមឃាត់ សម្រាប់អនីតិជន

អាយុ	មិនត្រូវធ្វើ	មិនត្រូវធ្វើការពេលណាក៏ដោយ
16 & 17	ល្ងាច**យប់** ពីម៉ោង ១០យប់ ដល់ ៦ព្រឹក (ប្រសើរសម្រាប់ ១០:១៥ បើគ្មានថ្ងៃធ្វើការ បុទីលែងបម្រើឡើងវិញម៉ោង ១០យប់) *លើកលែងតែ៖* យប់អតិរេក អាចធ្វើការដល់ម៉ោង ១១:៣០ យប់ ឬ ដល់កណ្តាលយប់ បើធ្វើការនៅគេដន៏ដ្ឋាន ឬកន្លែងប្រណាំងឡាន	• លើសពី **៩ម៉ោង** ក្នុងមួយថ្ងៃ • លើសពី **៤៨ម៉ោង** ក្នុងមួយសប្តាហ៍ • លើសពី **៦ថ្ងៃ**ក្នុងមួយសប្តាហ៍
14 & 15	ពេល**យប់** ពីម៉ោង ៧យប់ ដល់ ៧ព្រឹក *លើកលែង៖* នៅរដូវក្តៅ (១ កក្កដា ដល់ទិវាពលកម្ម) អាចធ្វើការដល់ម៉ោង ៩យប់។ **ក្នុងឆ្នាំសិក្សា:** • ក្នុងម៉ោងរៀន • លើសពី **៣ម៉ោង** ក្នុងថ្ងៃរៀន • លើសពី **១៨ម៉ោង** ក្នុងមួយសប្តាហ៍ • លើសពី **៨ម៉ោង** ថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាក.	**ពេលសាលាឈប់** • លើសពី **៨ម៉ោង** នៅថ្ងៃក៏ដោយ • លើសពី **៤០ម៉ោង** ក្នុងមួយសប្តាហ៍ • លើសពី **៦ថ្ងៃ**ក្នុងមួយសប្តាហ៍

** លើកលែង៖* សម្រាប់ការងារដែលសាលាអនុញ្ញាត ឬ ការងារសិលាងបទពិសោធន៍ សិស្សអាចទទួលការអនុញ្ញាត ឲ្យធ្វើការក្នុងថ្ងៃរៀនរហូតដល់ ២៣ម៉ោង ក្នុងមួយសប្តាហ៍។
ក្រោយម៉ោង ៨យប់ អនីតិជនទាំងអស់ត្រូវមានមនុស្សពេញវ័យតាមមើលការខុសត្រូវ។ ក្រោយម៉ោង ៨យប់ អនីតិជនទាំងអស់ ត្រូវតែមានមនុស្សពេញវ័យចាំមើលដាច់ខាត នៅកន្លែងធ្វើការ។ *លើកលែង៖* **មិនចាំបាច់មានមនុស្សពេញវ័យតាមមើលការខុសត្រូវទេ ចំពោះអនីតិជនធ្វើការតាមក្បួស ឬ តូបនៅកន្លែងមនុស្សអ៊ឹកអ៊ាក ក្នុងហាងទំនិញ ដែលមានសន្តិសុខយាម ពីម៉ោង ៨យប់ ហូតហាងទំនិញនោះបិទ។**

ទាំងនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗ ទាក់ទងនឹងកិច្ចការ ដែលច្បាប់ផ្តល់ និងច្បាប់ជាតិហាម។ បើអ្នកចង់ជ្រាបពត៌មានលម្អិតអំពីការងារដែលច្បាប់ហាមអនីតិជន មិនឲ្យធ្វើ សូមទាក់ទងផ្នែកយុត្តិធម៌ការងាររបស់ការិយាល័យអគ្គព្រះរាជអាជ្ញា៖ (617) 727-3465
www.mass.gov/ago/youthemployment ឬទាក់ទងនាយកដ្ឋានការងារសហរដ្ឋអាមេរិក៖ (617) 624-6700 *www.youth.dol.gov*

សូមទាក់ទងផ្នែកយុត្តិធម៌ការងារ របស់ការិយាល័យអគ្គរដ្ឋអាជ្ញា៖ (617) 727-3465 – www.mass.gov/ago/fairlabor

Rev. 12/2018